ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :..១៣..សរណន

# សារាចរណែនាំ
## ស្តីពី
## វិធានការការពារសុវត្ថិភាព
## មូលដ្ឋានគ្រឹះនៃប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា

ដើម្បីបង្កើតនូវប្រភពថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានស្ថេរភាព និងមានថ្លៃសមរម្យ រាជរដ្ឋាភិបាល បាននិង កំពុងយកចិត្តទុកដាក់អភិវឌ្ឍ និងជម្រុញការវិនិយោគសាងសង់ស្ថានីយ៍ផលិតអគ្គិសនី បណ្តាញជាតិបញ្ជូនថាមពល បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយ គួបផ្សំនិងការនាំចូលអគ្គិសនីពីប្រទេសជិតខាង សម្រាប់ផ្គត់ផ្គង់អគ្គិសនីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមនឹងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល បានសង្កេតឃើញមានជនខិលខូចបានធ្វើសកម្មភាព លួចបបនភ័ណ្ឌអគ្គិសនី និងបង្កសកម្មភាពប៉ះពាល់ដល់សុវត្ថិភាពទំនប់វារីអគ្គិសនី ស្ថានីយ៍ផលិតអគ្គិសនី អនុស្ថានីយ៍ និងប្រព័ន្ធបណ្តាញអគ្គិសនី នៅកន្លែងមួយចំនួន ដែលធ្វើឲ្យប៉ះពាល់ដល់ស្ថេរភាពក្នុងការផ្គត់ផ្គង់ គ្រោះថ្នាក់ដល់ប្រព័ន្ធបណ្តាញ ខូចខាតឧបករណ៍ប្រើប្រាស់ដែលកំពុងដំណើរការ រាំងស្ទះដល់កិច្ចដំណើរការសាងសង់ ការធ្វើអាជីវកម្ម ខូចខាតដល់ទ្រព្យសម្បត្តិ ផលប្រយោជន៍សាធារណៈ ព្រមទាំងបង្កគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស និងសត្វ។

ដើម្បីការពារសុវត្ថិភាពមូលដ្ឋានគ្រឹះនៃប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី មិនឲ្យទទួលរងនូវការបំផ្លិចផ្លាញដូចបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាល សូមធ្វើការណែនាំ ដូចតទៅ:

១. ហាមឃាត់ដាច់ខាត មិនឱ្យបុគ្គលណាមួយប្រព្រឹត្ត នូវរាល់អំពើទាំងឡាយណាដែលប៉ះពាល់ដល់សុវត្ថិភាពទំនប់វារីអគ្គិសនី ស្ថានីយ៍ផលិតអគ្គិសនី និងអនុស្ថានីយ៍អគ្គិសនី។

២. ហាមឃាត់ដាច់ខាតមិនឱ្យបុគ្គលណាមួយប្រព្រឹត្ត សកម្មភាពជីកគាស់កាយគ្រឹះបង្គោលអគ្គិសនី ដោះខ្ចៅ(ប៊ូឡុង)យកដែកបង្គោល ដោះបរិក្ខារអគ្គិសនីនៃប្រព័ន្ធបណ្តាញ កាត់យកខ្សែបណ្តាញ កាត់យកប្រព័ន្ធខ្សែដី កាត់យកខ្សែកាបអុបទិច (Optical Ground Wire) ឬប្រព្រឹត្តសកម្មភាពដែលប៉ះពាល់ដល់ខ្សែកាប ការជីកខួងដីក្នុងគន្លងខ្សែកាប ឬនៅក្បែរបង្គោលអគ្គិសនី ការលើកដាក់សំភារៈផ្សេងៗ និងការបង្ហោះខ្លែងនៅជិតបណ្តាញជាតិបញ្ជូនអគ្គិសនី ការឡើងបង្គោលអគ្គិសនី ។ល។ ការសាងសង់សំណង់ផ្សេងៗ និងការដាំដើមឈើក្នុងគន្លងខ្សែបណ្តាញ ដែលមិនត្រឹមត្រូវតាមស្តង់ដារបច្ចេកទេសអគ្គិសនី។

៣. គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត មានភារកិច្ចចាត់វិធានការដាក់ស្តែង ដើម្បីការពារសុវត្ថិភាពការដ្ឋានសំណង់អគ្គិសនី និងមូលដ្ឋានគ្រឹះនៃប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ក្នុងដែនដីទទួលខុសត្រូវរបស់

ខ្លួនឲ្យមានប្រសិទ្ធភាព មិនទុកឲ្យមានការប្រព្រឹត្តណាមួយធ្វើឲ្យប៉ះពាល់ ខូចខាត រាំងស្ទះ គ្រោះថ្នាក់ ដូចមានរៀបរាប់ខាងលើ និងត្រូវយកចិត្តទុកដាក់ អប់រំប្រជាពលរដ្ឋឲ្យយល់ដឹងពីតម្លៃ និងអត្ថប្រយោជន៍របស់មូលដ្ឋានគ្រឹះនៃប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ពីទំហំនៃការខូចខាត ពីគ្រោះថ្នាក់ដោយសារចរន្តអគ្គិសនី និងឲ្យចូលរួមជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីការពារការដ្ឋានសំណង់អគ្គិសនី និងមូលដ្ឋានគ្រឹះនៃប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី។

៤. កងកំលាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ អាជ្ញាធរមានសមត្ថកិច្ច មានកាតព្វកិច្ចការពារ និងសហការការពារការដ្ឋានសំណង់អគ្គិសនី និង មូលដ្ឋានគ្រឹះនៃប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី នៅក្នុងភូមិសាស្ត្រដែលខ្លួនបោះទីតាំងឲ្យមានសុវត្ថិភាព។

៥. បន្ទាប់ពីទទួលបាននូវព័ត៌មានអំពីសកម្មភាពប្រព្រឹត្តបទល្មើសដូចរៀបរាប់ខាងលើ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការអង្កេតស្រាវជ្រាវរកជនប្រព្រឹត្តបទល្មើស បញ្ជូនទៅតុលាការផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន្ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវចាត់ចែងផ្សព្វផ្សាយឲ្យបានទូលំទូលាយ និងអនុវត្តន៍តាមសមត្ថកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ៨ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***ចម្លងជូន***

*-ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ*
*-គណៈបញ្ជាការឯកភាពរាជធានី ខេត្ត*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*